**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**សាលក្រមព្រហ្មទណ្ឌ**
**លេខៈ ៣៩ (ថ)/៥៣២**
ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៨២
ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២១
-សំណុំរឿងជំនុំជម្រះលេខៈ ៤៦៨
ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជំនុំជម្រះជាសាធារណៈ សាលសវនាការលេខ ក២ អគារ ក នៃសាលាដំបូងខេត្តសៀមរាប នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ វេលារសៀល ដែលមានសមាសភាពចូលរួមដូចតទៅៈ

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ឋានៈចៅក្រមសាលាដំបូងខេត្តសៀមរាប

**តំណាងអយ្យការ**

លោក [redacted] ឋានៈព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ឋានៈក្រឡាបញ្ជីសាលាដំបូង

**ដើម្បីជំនុំជម្រះលើ** ៖ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៨២ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] សារឿន ភេទប្រុស កើតថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៧៩ ជនជាតិខ្មែរ មុខរបរអគ្គនាយកក្រុមហ៊ុន WE ALL PROPERTY កើតនៅភូមិ [redacted] ខេត្តកណ្ដាល កម្រិតវប្បធម៌បរិញ្ញាប័ត្រទេសចរណ៍ ទីលំនៅបច្ចុប្បន្ននៅភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] រ៉ា មានកូន ០៣ នាក់ ឪពុកឈ្មោះ [redacted] សុខ (រ) ម្ដាយឈ្មោះ [redacted] ភា (រ) ទោសពីមុន គ្មាន ។

ដីកាសម្រេចមិនឃុំខ្លួនលេខ ១២៣/២០២២ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ។

ជាប់ចោទពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិសាលាកំរើក សង្កាត់សាលា កំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ និងថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រម ព្រហ្មទណ្ឌ ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិ ។

**អង្គហេតុកើតឡើងមានដូចតទៅៈ**

កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ ឈ្មោះ [redacted] ប៊ុនធឿន បានចូលមកដាក់ពាក្យបណ្ដឹងនៅអយ្យការអមសាលាដំបូងខេត្តសៀមរាប ដែលបានប្ដឹងទៅលើឈ្មោះ [redacted] សារឿន ។ មូលហេតុនៃការប្ដឹងដោយសារ



Scanned with CamScanner

ឈ្មោះ [redacted] សារឿន មានតួនាទីជាអ្នកលក់ដី និងផ្ទះល្វែង បុរី ជឿន សុនីតា របស់ឈ្មោះ [redacted] ប៊ុនជឿន មានទីតាំងនៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដែលបានទទួលប្រាក់បង់របស់អតិថិជនឈ្មោះ [redacted] វិសាល កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ចំនួន ១.០០០(មួយពាន់) ដុល្លារអាមេរិក និងពីអតិថិជនឈ្មោះ [redacted] ខេមាណាវី ចំនួន ១.០០០ (មួយពាន់)ដុល្លារអាមេរិក កាលពី ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ហើយមិនបានបង្វិលប្រាក់ទាំងនេះចូលទៅក្រុមហ៊ុន ។

## **ភាគីដើមបណ្ដឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] ប៊ុនជឿន ភេទប្រុស អាយុ៤២ ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិ១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ប្ដឹងទាមទារសំណងប្រាក់បង់ទិញផ្ទះចំនួន ២.០០០(ពីរពាន់)ដុល្លារអាមេរិក និងសំណងជម្ងឺចិត្ត ១០.០០០(មួយម៉ឺន)ដុល្លារអាមេរិក ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ ។

បានឃើញៈ ដីកាសន្និដ្ឋានស្ថាពរលេខៈ ២៨៩ អយក/២២ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញៈ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ លេខៈ ២០៩៧ /២២ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

បានឃើញៈ ដីកាចាត់តាំងចៅក្រមជំនុំជម្រះ លេខៈ ៤៨២ ព្រស.ព្រជ(ក) ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## **នាពេលសវនាការ**

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សារឿន បានឆ្លើយថា ៖ ចំពោះខ្លឹមសារនៃពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] ប៊ុនជឿន ដែលបានប្ដឹងមកលើ ខ្លួនគឺខ្លួនសូមបដិសេធចោលទាំងស្រុងពីព្រោះមិនមែនជាការពិត ។ ជុំវិញការទូទាត់ប្រាក់របស់ អតិថិជនពីរនាក់មានឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ខេមាណាវី គឺខ្លួនទទួលស្គាល់ថាពិត ជាបានទទួលប្រាក់ចំនួន ១.០០០(មួយពាន់)ដុល្លារអាមេរិក កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ពី ឈ្មោះ [redacted] វិសាល មែន។ ហើយនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ខ្លួនពិតជាបានទទួលប្រាក់ ឈ្មោះ [redacted] ខេមាណាវី ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក តាមគណនីផ្ទាល់ខ្លួនមែន (ដោយសារកាលនោះពុំទាន់មានគណនីរួមរបស់ក្រុមហ៊ុន) ។ គ្រប់ពេលទទួលបានប្រាក់ពីអតិថិជន គឺខ្លួនបានកត់សម្គាល់ចំណាំទុកជាប្រចាំដោយមិនមានចេតនាបន្លំប្រាក់អ្វីទេ ។ បន្ទាប់មកខ្លួនបូកសរុបប្រាក់ដែលទទួលបានហើយយកទៅឱ្យគណនេយ្យបូកសរុបបញ្ជីដោយមិនមានខ្វះនោះទេ ។ ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ខ្លួនសំណូមពរសុំឱ្យតុលាការ មេត្តាលើកលែងចោទប្រកាន់មកលើខ្លួនផង។

-អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនជឿន បានឆ្លើយថា ៖ នៅអំឡុងខែ វិច្ឆិកា ឆ្នាំ២០២០ ខ្លួន និងឈ្មោះ [redacted] សារឿន បានសហការគ្នាធ្វើទីផ្សារក្នុងគោលបំណងលក់គម្រោងផ្ទះល្វែង (របស់ខ្លួន) មានចំនួន៦០ខ្នង មានទីតាំងនៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ ២០២០ និងថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០២០ មានឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ខេមាណាវី បានមកទិញគម្រោងផ្ទះល្វែងរបស់ខ្លួនខាងលើ ហើយបង់រំលោះក្នុងមួយខែ ១០០០ (មួយពាន់)



Scanned with CamScanner

ដុល្លារអាមេរិក តាមរយៈឈ្មោះ [redacted] សារឿន ។ ហើយនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ និងថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ជាថ្ងៃដែលឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ខេមាណារី ត្រូវបង់ប្រាក់មកឱ្យខ្លួនប៉ុន្តែដល់ថ្ងៃកំណត់ពុំឃើញទេ ទើបខ្លួនក៏បានសួរនាំទៅកាន់ឈ្មោះ [redacted] សារឿន ហើយឈ្មោះ [redacted] សារឿន បានប្រាប់ថា អតិថិជនទាំងពីរខាងលើពុំទាន់បានបង់ទេ ។ ទើបខ្លួនទំនាក់ទំនងផ្ទាល់ទៅឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ខេមាណារី ហើយពួកគាត់បានប្រាប់មកខ្លួនវិញ ថាពួកគាត់បានបង់ប្រាក់រួចរាល់តាមការកំណត់អស់ហើយ គឺបង់តាមរយៈធនាគារ ABA។ បន្ទាប់ មកឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ខេមាណារី បានផ្ញើប័ណ្ណព័ត៌មានរបស់ធនាគារមកឱ្យខ្លួន ផងដែរ។ បន្ទាប់ពីដឹងថាឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ខេមាណារី បានបង់ប្រាក់រួចរាល់ហើយខ្លួនបានព្យាយាមទំនាក់ទំនងទៅឈ្មោះ [redacted] សារឿន ជាច្រើនលើកប៉ុន្តែឈ្មោះ [redacted] សារឿន មិនអើពើ និងមិនប្រគល់ប្រាក់មកឱ្យខ្លួននោះទេ ។ ទើបខ្លួនសម្រេចចិត្តដាក់ពាក្យបណ្តឹងខ្លួនសំណូមពរសុំឱ្យតុលាការមេត្តាជួយរកយុត្តិធម៌ដល់ខ្លួនផង និងសុំឲ្យឈ្មោះ [redacted] សារឿន សងប្រាក់មកខ្លួនវិញចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ព្រមទាំងទាមទារសំណងជម្ងឺចិត្តថ្លៃខូចខាតជាប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ចិន្តា បានឆ្លើយថា ៖ ចំពោះរឿងហេតុដែលឈ្មោះ [redacted] ប៊ុនធឿន ប្តឹងទៅលើ ឈ្មោះ [redacted] សារឿន ពាក់ព័ន្ធទៅនឹង ករណីរំលោភលើទំនុកចិត្តគឺខ្លួនពុំបានដឹងទេ ។ រឿងហេតុដែលខ្លួនបាន ដឹងគឺក្រុមហ៊ុន បុរីធឿន សុជាតា លក់ផ្ទះល្វែងគឺមានឈ្មោះ [redacted] ប៊ុនធឿន និងប្រពន្ធជាម្ចាស់ក្រុមហ៊ុន ។ ចំណែកឯឈ្មោះ [redacted] សារឿន មិនមែនជាម្ចាស់ក្រុមហ៊ុនទេ តែគាត់ជាតំណាងក្នុងការលក់គម្រោងផ្ទះល្វែង ឱ្យឈ្មោះ [redacted] ប៊ុនធឿន ។ ចំពោះខ្លួនជាបុគ្គលិកផ្ទាល់របស់ឈ្មោះ [redacted] សារឿន ដែលកាន់កាប់ផ្នែករដ្ឋបាល និងគណនេយ្យ ។ រាល់ការទូទាត់ប្រាក់របស់អតិថិជនទាំងអស់ ដែលបានទិញគម្រោងគឺពេលខ្លះបានទូទាត់ ប្រាក់ផ្ទាល់ជាមួយឈ្មោះ [redacted] សារឿន (ប្រគល់ប្រាក់សុទ្ធ ឬ វេរតាមគណនី) ហើយពេលខ្លះអតិថិជនបាន ប្រគល់ប្រាក់ឱ្យខ្លួនផ្ទាល់ ។ ចំពោះឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ខេមាណារី គឺខ្លួនស្គាល់ពួកគាត់ទាំងពីរ ដោយពួកគាត់បានចូលមកទិញគម្រោងផ្ទះរបស់ឈ្មោះ [redacted] ប៊ុនធឿន តាមរយៈឈ្មោះ [redacted] សារឿន ។ នៅអំឡុងខែមីនា ឆ្នាំ២០២១ ឈ្មោះ [redacted] សារឿន បានសាកសួរខ្លួនថាតើឈ្មោះ ជាវ ប៊ុនធឿន បានទូទាត់ប្រាក់ ថ្លៃកម្រៃជើងសារតាមកិច្ចសន្យាមកឬទេ ហើយខ្លួនក៏បានតបថាពុំទាន់បានទូទាត់ឱ្យនោះទេ បន្ទាប់មកឈ្មោះ [redacted] សារឿន បានប្រាប់ឱ្យខ្លួនកាត់ប្រាក់ចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ចាត់ទុកថាកាត់ បំណុលដែលឈ្មោះ [redacted] ប៊ុនធឿន មិនទាន់បានទូទាត់ថ្លៃកម្រៃជើងសារ ។ ក្រោយមកខ្លួនបានកាត់ប្រាក់ចំនួន ២.០០០ (ពីរពាន់)ដុល្លារអាមេរិក ដែលប្រាក់នេះជាប្រាក់ទូទៅនៅក្នុងគណនេយ្យខ្លួនពុំបានសម្គាល់ថាជា ប្រាក់អតិថិជនណាមួយទេ ។ ចំពោះទំនាក់ទំនងរវាងឈ្មោះ [redacted] ប៊ុនធឿន និង ឈ្មោះ [redacted] សារឿន ជុំវិញបញ្ហាការទូទាត់ប្រាក់របស់អតិថិជនឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ខេមាណារី ខ្លួនពុំបានដឹងស៊ីជម្រៅនោះទេ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមសវនាការបាន ស្តាប់ចម្លើយជនជាប់ចោទ និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារឿន ជាអ្នកលក់គម្រោងបុរីផ្ទះ ល្វែងរបស់ជនរងគ្រោះ ។ អតិថិជនឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ខេមាណារី

បានមកទិញផ្ទះល្វែងនៅក្នុង បុរីរបស់ជនរងគ្រោះតាមរយៈឈ្មោះ [redacted]សារឿន បានបង់រំលោះក្នុង ១ ខែចំនួន ១.០០០ (មួយពាន់) ដុល្លារ អាមេរិក តាមការត្រួតពិនិត្យការបង់ប្រាក់ជាក់ស្តែងអតិថិជនទាំង ២ បានបង់ប្រាក់តាមកាលកំណត់តែឈ្មោះ [redacted] សារឿន មិនបានយកប្រាក់ដាក់មកក្នុងក្រុមហ៊ុន និងមានចេតនាគេចវេះ ហេតុនេះសូមចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទ និងសម្រេចពីសំណងរដ្ឋប្បវេណីតាមការទាមទាររបស់ជនរងគ្រោះ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន និងប្តឹងសុំថា ឆ្លងតាមការដេញដោលនាសវនាការ និងស្តាប់ចម្លើយឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា អតិថិជនឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ខេមាណាវី ដែលទិញផ្ទះល្វែងដោយបង់រំលោះក្នុងមួយខែ ១.០០០(មួយពាន់) ដុល្លារអាមេរិក តាមការត្រួតពិនិត្យគណនីឃើញថា អតិថិជនបានបង់ប្រាក់តាមកាលកំណត់ តែជនជាប់ចោទមិនបានបំពេញកាតព្វកិច្ចបញ្ចូលប្រាក់ទៅក្រុមហ៊ុន តំណាងអយ្យការសម្រេចរក្សាបទចោទប្រកាន់ប្តឹងសុំចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមសវនាការបានស្តាប់ចម្លើយជនជាប់ចោទ និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឃើញថា ជនជាប់ចោទមិនបានប្រព្រឹត្តដូចការចោទប្រកាន់តាមដីកា សន្និដ្ឋានស្ពាព និងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះទេ ។ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ពិតមានកិច្ចសន្យាគម្រោងលក់ផ្ទះក្នុងបុរីរបស់ជនរងគ្រោះមែនដោយមានការបែងចែកភាគលាភទៅជនជាប់ចោទ ។ ក្នុងនាមជាអ្នកលក់គម្រោងជនជាប់ចោទមានសិទ្ធិទទួលប្រាក់ពីអតិថិជនដោយក្រុមហ៊ុនមិនទាន់មានគណនីរួមហើយជនជាប់ចោទក៏មិនបានកិបកេងបានទូទាត់ទៅក្រុមហ៊ុនគ្រប់ចំនួនដូចការអះអាងរបស់សាក្សី ឈ្មោះ [redacted] ចិន្តា ។ ចំពោះការអះអាងរបស់ជនរងគ្រោះថា បានប្រគល់ចំនួន ១.០០០ (មួយពាន់) ដុល្លារអា មេរិក ដើម្បីបើក គណនីរួមនេះមិនពិតទេ គឺប្រាក់នេះសម្រាប់រៀបចំពិធីបើកការដ្ឋានសាងសង់ដែលត្រូវចំណាយ ផ្សេងៗ ។ នៅ ក្នុងកិច្ចសន្យាចំណុច ៤ បានបញ្ជាក់ថា ជនជាប់ចោទមានសិទ្ធិក្នុងប្រតិបត្តិការទទួលប្រាក់ពីអតិថិជន និងទូទាត់តាមខែចូលទៅក្រុមហ៊ុន ។ ជាក់ស្តែងជនជាប់ចោទបានលក់ផ្ទះល្វែងឱ្យអតិថិជនបាន ២០ ល្វែងហើយជនរង គ្រោះមិនទាន់បានទូទាត់ភាគលាភឱ្យជនជាប់ចោទឡើយ ។ ការទូទាត់ប្រាក់ចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ពីគណនីគឺជាប្រតិបត្តិការដែលមានទទួលផលលាភមិនមែនជាការរំលោភលើទំនុកចិត្តទេហេតុនេះ ឃើញថាមិនមានភស្តុតាងបញ្ជាក់ពីបទចោទដូចការចោទប្រកាន់មកលើជនជាប់ចោទទេ ខ្លួនសំណូមពរសុំឱ្យចៅក្រមជំនុំជម្រះសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទប្រកាន់ ។

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ ។

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ ជាដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យកស្តុតាង និងឯកសារនានាក្នុងសំណុំរឿង ។

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សំអាងហេតុ

១-តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨២ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០២១ តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ លេខៈ ២០៩៧ /២២ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សារឿន ភេទប្រុស កើតថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៧៤ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មកជំនុំជម្រះពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ និងថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២-តាមកិច្ចព្រមព្រៀងបែងចែកភាគលាភ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ឈ្មោះ [redacted] ប៊ុនធឿន ដែលមានដីផ្ទាល់ខ្លួនស្ថិតនៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្ត សៀមរាប បានយល់ព្រមឱ្យឈ្មោះ [redacted] សារឿន ធ្វើជាអ្នកទីផ្សារដើម្បីស្វែងរកអតិថិជនមកទិញដី និង ផ្ទះដោយឈ្មោះ [redacted] សារឿន បានទទួលប្រាក់កម្រៃជើងសារចំនួន ៦% នៃតម្លៃដែលអតិថិជនបាន ទិញជាក់ស្តែង ។

៣-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនធឿន បានបញ្ជាក់ថា នៅអំឡុង ខែវិច្ឆិកា ឆ្នាំ២០២០ ខ្លួន និងឈ្មោះ [redacted] សារឿន បានសហការគ្នាធ្វើទីផ្សារក្នុងគោលបំណងលក់គម្រោងផ្ទះល្វែងរបស់ខ្លួន ដោយឈ្មោះ [redacted] សារឿន ជាអ្នករកទីផ្សារ និងទទួលបានផលលាភចំនួន ៦% លើតម្លៃទិញដី និងផ្ទះជាក់ស្តែង ។ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ មានអតិថិជនឈ្មោះ [redacted] ខេមាណវី បានមកទិញគម្រោងផ្ទះល្វែងដោយបង់រំលោះក្នុង ១ ខែ ១,០០០ (មួយពាន់)ដុល្លារអាមេរិក ហើយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០ មានអតិថិជនឈ្មោះ [redacted] វិសាល បានមកទិញគម្រោងផ្ទះល្វែង ដោយបង់រំលោះក្នុង ១ ខែ ១,០០០ (មួយពាន់) ដុល្លារអាមេរិក ។ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ឈ្មោះ [redacted] វិសាល បានបង់ប្រាក់រំលោះប្រចាំខែចំនួន ១,០០០ (មួយពាន់) ដុល្លារអាមេរិក ហើយនៅ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ឈ្មោះ [redacted] ខេមាណវី បានបង់ប្រាក់រំលោះប្រចាំខែចំនួន ១,០០០ (មួយពាន់) ដុល្លារអាមេរិក ដោយផ្ទេរតាមគណនី ABA មកឱ្យឈ្មោះ [redacted] សារឿន តែឈ្មោះ [redacted] សារឿន មិនបានយកប្រាក់ដែលអតិថិជនបង់នេះប្រគល់មកឱ្យក្រុមហ៊ុន ។ ការអះអាងរបស់ដើម បណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុនធឿន មិនមានភស្តុតាងបញ្ជាក់ពីប្រតិបត្តិការបញ្ជូនប្រាក់របស់ឈ្មោះ [redacted] សារឿន ឡើយ ។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារឿន បញ្ជាក់ថា ខ្លួនជាអ្នករកទីផ្សារមក ទិញដី និងផ្ទះល្វែងឱ្យឈ្មោះ [redacted] ប៊ុនធឿន ដោយទទួលផលលាភ ៦% លើតម្លៃទិញដី និងផ្ទះជាក់ស្តែង ។ ខ្លួនពិតបានទទួលប្រាក់ពីអតិថិជនឈ្មោះ [redacted] វិសាល និងឈ្មោះ [redacted] ខេមាណវី ដែលបង់ រំលោះប្រចាំខែចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក តាមរយៈគណនីរបស់ខ្លួន ដោយពេលនោះមិនទាន់មានគណនីរួមរបស់ក្រុមហ៊ុន ហើយខ្លួនបានកត់សម្គាល់ទុកជាប្រចាំ និងបានបូកសរុបប្រាក់ដែលទទួលបាន និងយកទៅឱ្យគណនីបូកសរុបបញ្ជីដោយមិនមានខ្វះខាតនោះទេ។

៥-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ចិន្តា បានបញ្ជាក់ថា ខ្លួនជាបុគ្គលិកផ្នែករដ្ឋបាល និងគណនេយ្យ ។ រាល់ការទូទាត់ប្រាក់របស់អតិថិជនដែលបានទិញគម្រោងដី និងផ្ទះល្វែងពេលខ្លះបានទូទាត់

ជាមួយឈ្មោះ [redacted]សារឿន ជាតំណាងក្នុងការលក់គម្រោងតាមរយៈការប្រគល់ប្រាក់សុទ្ធ ឬផ្ទេរតាមគណនី ហើយពេលខ្លះអតិថិជនបានប្រគល់ប្រាក់មកឱ្យខ្លួនផ្ទាល់ ។ អតិថិជនឈ្មោះ [redacted]វិសាល និងឈ្មោះ [redacted] ខេមាណរី ពិតបានមកទិញគម្រោងតាមរយៈឈ្មោះ [redacted]សារឿន ។ នៅអំឡុង ខែមីនា ឆ្នាំ២០២១ ឈ្មោះ[redacted] សារឿន ពិតបានសួរខ្លួនពីប្រាក់កម្រៃជើងសារតាមកិច្ចសន្យា និងបាន ប្រាប់ឱ្យខ្លួនកាត់ប្រាក់ចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ចាត់ទុកជាបំណុលដែលឈ្មោះ[redacted]ប៊ុនធឿន មិនទាន់បានទូទាត់កម្រៃជើងសារ ហើយខ្លួនបានកាត់ប្រាក់នៅក្នុងគណនីទូទៅមិនបាន សម្គាល់ថាជាប្រាក់អតិថិជនណាមួយទេ ។

៦-សរុបការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ការអះអាងរបស់ជនជាប់ចោទ ចម្លើយបំភ្លឺរបស់សាក្សី និងភស្តុតាងជាឯកសារឃើញថា ការប្តឹងចោទប្រកាន់របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ប៊ុនធឿន ជាម្ចាស់គម្រោងលើឈ្មោះ[redacted]សារឿន ដែលជាអ្នករកទីផ្សារក្នុងការដែលឈ្មោះ [redacted] សារឿន ទទួលប្រាក់ពីអតិថិជន មិនប្រគល់ប្រាក់មកក្រុមហ៊ុនមិនមានភស្តុតាងបញ្ជាក់ជាក់លាក់ ដោយហេតុថាតាមកិច្ចព្រមព្រៀងបែងចែក ភាគលាភរបស់ភាគី មិនបានកំណត់ពីប្រតិបត្តិការប្រាក់ដែលអតិថិជនត្រូវបង់តាមរយៈណាឡើយ ហើយក៏មិនបានកំណត់ពីរយៈពេលដែលទទួលប្រាក់ពីអតិថិជន និងរយៈពេលប្រគល់ប្រាក់ទៅក្រុមហ៊ុនដែរ ។ ម៉្យាងការ អះអាងរបស់ឈ្មោះ [redacted]ប៊ុនធឿន ថាមិនបានទទួលប្រាក់ពីឈ្មោះ [redacted] សារឿន ក៏មិនមានភស្តុតាងបញ្ជាក់ផងដែរ ។

៧-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ប៊ុនធឿន បានសន្និដ្ឋានបញ្ជាក់ថា អតិថិជនឈ្មោះ [redacted] វិសាល និងឈ្មោះ[redacted] ខេមាណរី ដែលទិញគម្រោងដី និងផ្ទះរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ប៊ុនធឿន បានបង់ប្រាក់រំលោះក្នុង ១ ខែ ១.០០០ (មួយពាន់) ដុល្លារអាមេរិក តាមកាលកំណត់ តែឈ្មោះ [redacted]សារឿន ដែលជាអ្នកទីផ្សារមិនបានយកប្រាក់ដាក់មកក្នុងក្រុមហ៊ុន និងមានចេតនាគេចវេះ ជាការសន្និដ្ឋានដោយការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនមានភស្តុតាងបញ្ជាក់អាចឱ្យតុលាការពិចារណា ។

៨-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការ បានសន្និដ្ឋានបញ្ជាក់ពីភស្តុតាងដាក់បន្ទុកតាមរយៈការបង់ប្រាក់របស់អតិថិជន តែជនជាប់ចោទមិនបានបំពេញកាតព្វកិច្ចបញ្ចូលប្រាក់ទៅក្នុងក្រុមហ៊ុន រក្សាបទចោទប្រកាន់ និងប្តឹងសុំចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតុលាការ គប្បីពិចារណាតាមផ្លូវច្បាប់ ។

៩-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]សារឿន បានសន្និដ្ឋាន ថា ជនជាប់ចោទពិតបានទទួលប្រាក់ពីអតិថិជនឈ្មោះ [redacted]វិសាល និងឈ្មោះ [redacted] ខេមាណរី ដែលទិញ គម្រោងដី និងផ្ទះបង់រំលោះចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក និងបានទូទាត់ទៅក្រុមហ៊ុនគ្រប់ចំនួនដោយមានសាក្សីឈ្មោះ [redacted] ចិន្តា ហើយការដកប្រាក់ចំនួន ២.០០០ (ពីរពាន់) ដុល្លារ អាមេរិក ពីគណនី គឺជាការទូទាត់ផលលាភដែលមានចែងនៅក្នុងប្រការ៤ នៃកិច្ចព្រមព្រៀងទទួលផលលាភការចោទប្រកាន់ លើជនជាប់ចោទមិនមានភស្តុតាងបញ្ជាក់ និងសុំឱ្យចៅក្រមជំនុំជម្រះសម្រេចឱ្យ ជនជាប់ចោទរួចផុតពីបទចោទប្រកាន់មានលក្ខណៈត្រឹមត្រូវតុលាការគប្បីពិចារណា ។

## ហេតុដូច្នេះ សម្រេច

-ឱ្យឈ្មោះ [redacted] **សារឿន** (មានអត្តសញ្ញាណដូចខាងលើ) រួចខ្លួនពីបទចោទប្រកាន់ ពីបទ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពី ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ និងថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ ។



Scanned with CamScanner

-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារឿន និងដើមបណ្តឹងឈ្មោះ [redacted] ប៊ុនធឿន ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ១៤ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
សៀមរាប , ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]



Scanned with CamScanner